**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៧២ ដនស/អសណ

ថ្ងៃ អង្គារ ១ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២៤

## លិខិតអនុញ្ញាតសាងសង់

**យោង** ៖ - ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់

- អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- អនុក្រឹត្យលេខ ២២៥ អនក្រ.បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសអន្តរក្រសួងលេខ ៣៥៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតសាងសង់ និងប្លង់ស្ថាបត្យកម្មលេខ ៣៤៣ ដនស/អដន ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់លេខ ០៥១ អសណ/នសណ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានសំណង់
- លិខិតបិទការដ្ឋានសំណង់លេខ ០៥៣ អសណ/នសណ ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២ របស់អគ្គនាយកដ្ឋានសំណង់
- ពាក្យស្នើសុំចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០២៤ របស់ក្រុមហ៊ុន វិជ្ជូល អូវើស៊ី ឯ.ក តំណាងដោយលោក YANG XIANBO

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុញ្ញាតឱ្យកែសម្រួលប្លង់ស្ថាបត្យកម្មមួយផ្នែកនៅជាន់ផ្ទាល់ដី និងជាន់ទី ០១ នៃអគារស្នាក់នៅរួម ចំនួន ០១ អគារ កម្ពស់អតិបរមា ៦៩,៧០ ម៉ែត្រ មានជាន់ក្រោមដី ០១ ជាន់-ជាន់ផ្ទាល់ដី ជាន់ទី ១ ដល់ជាន់ទី ២១ និងដំបូលទែរ៉ាស់ មានផ្ទៃក្រឡាសំណង់កែសម្រួលសរុប ២.៤៨៩,០០ ម៉ែត្រការ៉េ នៅលើដីឡូត៍ទំហំ ១៦.៣២៧,០០ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៨០២០៦-០៦៧៩ មហាវិថីសហព័ន្ធរុស្ស៊ី (១១០) ភូមិបុរី ១០០ ខ្នង សង្កាត់ទឹកថ្លា

ខណ្ឌសែនសុខ រាជធានីភ្នំពេញ របស់ក្រុមហ៊ុន វិដ្ឋល អូវើស៊ី ឯ.ក តំណាងដោយលោក YANG XIANBO ដោយម្ចាស់សំណង់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

១. ត្រូវរៀបចំឱ្យមានសួនជ្រាបទឹកឱ្យបានយ៉ាងតិច ៣០ % នៃផ្ទៃដីឡូត៍ដែលនៅសល់ពីការសាងសង់ ត្រូវដាំដើមឈើ និងរុក្ខជាតិបៃតងឲ្យបានអតិបរមា ត្រូវរៀបចំផែនការសាងសង់ និងប្រើប្រាស់អគារសន្សំសំចៃថាមពល និងត្រូវប្រើប្រាស់សម្ភារៈសំណង់សមស្របដែលរួមចំណែកដល់គោលនយោបាយជាតិអភិវឌ្ឍន៍បៃតងរបស់រាជរដ្ឋាភិបាល។

២. ហាមប្រើប្រាស់ផ្លូវ ចិញ្ចើមផ្លូវ ទីធ្លាសាធារណៈជាចំណតយានយន្ត កន្លែងទុកដាក់សម្ភារៈសំណង់ និងឧបករណ៍សំណង់ គ្រឿងចក្រសាងសង់ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

៣. ត្រូវរៀបចំឱ្យមានពន្លឺ និងខ្យល់ចេញចូលគ្រប់គ្រាន់ក្នុងអគារ និងក្នុងបន្ទប់រស់នៅស្របតាមបទដ្ឋានបច្ចេកទេស និងត្រូវបំពាក់សម្ភារៈសំណង់ដែលមិនប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ សុខភាពបរិស្ថាន និងសង្គម និងសោភណភាពអគារឲ្យមានលក្ខណៈស្ថាបត្យកម្មល្អសមស្រប។

៤. ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងសំណល់រឹង-រាវ រៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ បំពាក់ម៉ាស៊ីនចម្រោះទឹកកខ្វក់ ប្រព័ន្ធលូស្របតាមមុខងារប្រើប្រាស់អគារមុនបង្ហូរចេញ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធអគ្គិសនី ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដោយមានការពិនិត្យយល់ព្រមពីសមត្ថកិច្ចជំនាញពាក់ព័ន្ធ ព្រមទាំងប្រើប្រាស់បច្ចេកទេសសាងសង់សមស្រប ដើម្បីធានាសុវត្ថិភាពដល់សំណង់ជិតខាង ការពារបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខុមាលភាពសង្គម។

៥. ត្រូវសិក្សាប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យស្របតាមបទដ្ឋានបច្ចេកទេស និងមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ។

៦. ត្រូវអនុវត្តតាមខ្លឹមសារដែលមានចែងក្នុងសៀវភៅគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងសុខភាពនៅការដ្ឋានសំណង់។

៧. ត្រូវសុំការអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីមានការកែប្រែមុខងារអគារ សោភណភាពអគារ ឬការសាងសង់បន្ថែមផ្សេងៗ ។

លិខិតអនុញ្ញាតសាងសង់នឹងត្រូវអស់សុពលភាព បើការងារសាងសង់ពុំត្រូវបានដំណើរការក្នុងរយៈពេល ១ (មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឡេង និព្វសីហា

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងបរិស្ថាន
-ក្រសួងរ៉ែ និងថាមពល
-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-រដ្ឋបាលរាជធានីភ្នំពេញ
-អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់
-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ
-មន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ
-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខណ្ឌសែនសុខ
-ការិយាល័យបង្ការ និងពន្លត់អគ្គិភ័យ នៃស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ
-ឯកសារ-កាលប្បវត្តិ